**AUSTRALIAN EMBASSY**
**PHNOM PENH**

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០២១

## ប្រទេសអូស្ត្រាលី គាំទ្រការស្តារសេដ្ឋកិច្ចប្រទេសកម្ពុជាឡើងវិញ តាមរយៈភាពជាដៃគូមេគង្គ-អូស្ត្រាលី

ថ្ងៃនេះ ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជា ឯកឧត្តម Pablo Kang បានបង្ហាញសង្ខេបជូនចំពោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីកម្មវិធីជំនួយថ្មីៗរបស់អូស្ត្រាលី ក្នុងប្រទេសកម្ពុជា ក្រោមភាពជាដៃគូមេគង្គ-អូស្ត្រាលី។

ក្រោមភាពជាដៃគូមេគង្គ-អូស្ត្រាលី ប្រទេសអូស្ត្រាលីនឹងផ្តល់នូវធនធានថ្មី ដើម្បីគាំទ្រការធ្វើទំនើបនីយកម្មដល់វិស័យកសិកម្មកម្ពុជា និងការអភិវឌ្ឍឧស្សាហកម្មកែច្នៃកសិផល ដែលជាធាតុសំខាន់នៃយុទ្ធសាស្ត្រស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញ។

កំឡុងកិច្ចប្រជុំ ឯកអគ្គរាជទូត និង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានចូលរួមជាធ្វើជាសាក្សីទៅលើការចុះហត្ថលេខាអនុស្សារណៈនៃការយោគយល់គ្នា រវាង កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី (CAVAC) និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ស្តីពីការផ្តល់ការគាំទ្រក្នុងការបង្កើតសួនឧស្សាហកម្មកសិចំណីអាហារ (AIP)។

ឯកអគ្គរាជទូត Pablo Kang បានលើកឡើងថា "ផលរំខានចំបងបង្កឡើងដោយជំងឺកូវីដ-១៩ មានន័យថា កម្ពុជាត្រូវស្វែងរកធនធានថ្មីៗ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន។ តាមរយៈភាពជាដៃគូមេគង្គ-អូស្ត្រាលី ពួកយើងមានសេចក្តីរីករាយ ក្នុងការជួយគាំទ្រកិច្ចខិតខំប្រឹងប្រែង ដើម្បីផ្តួចផ្តើមដំណើរការវិស័យកែច្នៃកសិផល ដែលនៅមានភាពក្មេងខ្ចីនៅឡើយ ប៉ុន្តែមានសក្តានុពលពិត ដើម្បីជំរុញការស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញ"។

ក្រោមអនុស្សារណៈនៃការយោគយល់គ្នានេះ CAVAC នឹងផ្តល់ការគាំទ្របច្ចេកទេស និងថវិកាជួយទៅដល់ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីបង្កើត និងអនុវត្តគំរូសេដ្ឋកិច្ចសមស្របមួយ សម្រាប់សួនឧស្សាហកម្មកសិចំណីអាហារ (AIP)។ AIP គឺជាតំបន់ឧស្សាហកម្ម ដែលផ្តោតលើការកែច្នៃកសិផលដោយមានសេវាផ្តល់ជូន

រួមជាលក្ខណៈ "ប្រកចេញ-ចូលតែមួយ" អនុលោមតាមបទប្បញ្ញត្តិ និងសណ្ឋានផ្សេងៗ ដូចជាការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងគ្រឿងបរិក្ខារធ្វើតេស្តសាកល្បងរួម។ កិច្ចការនេះ បង្កើតអោយមានសុគតភាព និងអាចពង្រីក ដើម្បីជួយដល់កម្ពុជាប្រកួតប្រជែងជាមួយ ស្ថាប័នកែច្នៃកសិចំណីអាហារ នៅក្នុងប្រទេសជិតខាង។

ជំនួយរបស់ CAVAC នឹងបញ្ចូលការសិក្សាពេញលេញមួយអំពីលទ្ធភាពនៃការបង្កើតគម្រោង និងការសិក្សាទីតាំងពាណិជ្ជកម្មជាក់លាក់ រួមមានការវិភាគលើផលប្រយោជន៍ ដែលកសិករទទួលបាន នៅតាមតំបន់ក្បែរទីតាំងគម្រោង និងអនុសាសន៍សម្រាប់ក្របខណ្ឌបញ្ញត្តិ ដែលផ្តល់អំណោយផលល្អជាងគេ។ កិច្ចការនេះផងដែរ នឹងត្រូវបន្ថែមទៅលើការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំ និងប្រព្រឹត្តទៅនៃយុទ្ធនាការអន្តរជាតិ ក្នុងការទាក់ទាញវិនិយោគទុនលើវិស័យកសិចំណីអាហារ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ថា "អាទិភាពចំពោះមុខរបស់រដ្ឋាភិបាល គឺប្រយុទ្ធប្រឆាំងនឹងការរីករាលដាលជំងឺកូវីដ-១៩ និង ការកសាងសមត្ថភាពកម្ពុជា ដើម្បីអាចរស់នៅជាមួយជំងឺកូវីដ-១៩ ក្នុងរយៈពេលមធ្យម និង វែង។"

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី បានបន្ថែមទៀតថា "អំឡុងពេលនេះ រាជរដ្ឋាភិបាលកំពុងរៀបចំផែនការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩ ដោយផ្តោតលើគោលការណ៍គន្លឹះចំនួនបីគឺ ការងើបឡើងវិញ កំណែទម្រង់ និង ភាពធន់ (៣Rs) ដែលផ្តោតលើការគាំទ្រវិស័យអាទិភាពជាច្រើន ជាពិសេសវិស័យដែលរងផលប៉ះពាល់ខ្លាំងដោយវិបត្តិជំងឺកូវីដ-១៩។"

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី បានបន្តទៀតថា ជំនួយហិរញ្ញវត្ថុ និង បច្ចេកទេសរបស់រដ្ឋាភិបាលអូស្ត្រាលី គឺនឹងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការសម្រេចឱ្យបាននូវ អាទិភាពគោលនយោបាយរបស់រដ្ឋាភិបាល ក្នុងបរិបទនៃការរីករាលដាលជំងឺកូវីដ-១៩ ដែលនឹងរួមចំណែកយ៉ាងសំខាន់ជាមួយ រាជរដ្ឋាភិបាលកម្ពុជា ក្នុងអនុវត្តផែនការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ ។

**សាវតា**

ភាពជាដៃគូមេគង្គ-អូស្ត្រាលី គឺជាកញ្ចប់ថវិកាជំនួយចំនួន ២៣២ លានដុល្លារអូស្ត្រាលី សម្រាប់រយៈពេល៤ឆ្នាំ ដើម្បីជួយដល់ការស្តារសេដ្ឋកិច្ចឡើងវិញ ក្នុងអនុតំបន់ទន្លេមេគង្គពីជំងឺកូវីដ-១៩ និងបង្កើតភាពធន់ចំពោះសេដ្ឋកិច្ច និងបរិស្ថានក្នុងតំបន់។ តាមរយៈភាពជាដៃគូមេគង្គ-អូស្ត្រាលី ប្រទេសអូស្ត្រាលីបានផ្តួចផ្តើមសកម្មភាពថ្មីៗមួយចំនួន រួមមានថាមពលកកើតឡើងវិញ ធនធានទឹក ការការពារអ្នកប្រើប្រាស់ អាហារូបករណ៍ សន្តិសុខបច្ចេកវិទ្យា និងការពង្រឹងវិនិយោគទុន។ ចំណែកនៃថវិកាដំបូងចំនួន ៥,៥ លានដុល្លារអូស្ត្រាលី (៤ លានដុល្លារសហរដ្ឋអាមេរិក) ត្រូវបានចំណាយសម្រាប់សកម្មភាព នៅកម្ពុជា ក្នុងខែ មិថុនា ឆ្នាំ២០២១ ជាមួយនឹងចំណែកផ្សេងៗទៀតកំពុងត្រូវបានរៀបចំ សម្រាប់ឆ្នាំ២០២១-២០២២ បន្ថែមលើកម្មវិធីជំនួយទាំងអស់ បច្ចុប្បន្នប្រមាណ ៦៦លានដុល្លារអូស្ត្រាលី (៤៨ លានដុល្លារសហរដ្ឋអាមេរិក)៕

សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងតាមរយៈ Australian.Embassy.Cambodia@dfat.gov.au